# សន្តិភាវូបនីយកម្មនៅកម្ពុជា
# (១៩៩១-១៩៩៨)



***ទុយ យូឃីម***
*បណ្ឌិតវិទ្យាសាស្ត្រនយោបាយ*
*អនុប្រធានផ្នែកវិទ្យាសាស្ត្រអប់រំ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

ប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងភ្លើងសង្គ្រាមដ៏រ៉ាំរ៉ៃអស់រយៈពេលជាងបីទសវត្សរ៍ ដែលជាលទ្ធផលនៃឥទ្ធិពលមនោគមវិជ្ជាសង្គមនិយម និងមនោគមវិជ្ជាសេរី។

ក្រោយពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាគឺ សម្តេចនរោត្តម*សីហនុ* ព្រះអង្គបានជ្រើសរើសយកនយោបាយអព្យាក្រិតមកអនុវត្តក្នុងគោលបំណងស្វែងរកការគាំទ្រពីសហគមន៍អន្តរជាតិ។ ការប្រកាន់យកនយោបាយនេះក្នុងដំណាក់កាលនោះ វាជាគ្រោះថ្នាក់មួយសម្រាប់កម្ពុជាដែលទើបតែងើបចេញការគ្រប់គ្រងរបស់បារាំង វាជាការប្រឈមមុខយ៉ាងសម្បើមរបស់កម្ពុជាក្នុងដំណាក់កាលសង្គ្រាមត្រជាក់។ ប្រទេសកម្ពុជាបានទទួលនូវស្ថានភាពដ៏តឹងតែងមួយរបស់មហាអំណាច ក្នុងទិសដៅប្រើនូវមនោគមវិជ្ជារបស់ខ្លួនដើម្បីទប់ស្កាត់ និង រារាំងការឆ្លងគ្នាទៅវិញទៅមកនៃនមនោគមវិជ្ជាលោកសេរី និងពួកកុម្មុយនីស្ត។

យើងដឹងហើយថា ចាប់តាំងពីពេលដែលមានការបែកចេញនូវមនោគមវិជ្ជាពីរ រវាងសេរី និងសង្គមនិយមមក ឥទ្ធិពលនេះបានសាយភាយពាសពេញពិភពលោក ក្នុងនោះកម្ពុជាក៏បានក្លាយទៅជាសមរភូមិដ៏ក្តៅគគុករបស់មហាអំណាចទាំងនោះ ដើម្បីឱ្យកម្ពុជាស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួនដែរ។

ប្រទេសកម្ពុជា ជាប្រទេសតូចមួយដែលតែងតែបានទទួលឥទ្ធិពលពីបណ្តាប្រទេសមហាអំណាចមួយចំនួនតួយ៉ាងដូចជា សហរដ្ឋអាមេរិក សហភាពសូវៀត ចិនប្រជាមានិត បារាំង និងជប៉ុនជាដើម។ ឥទ្ធិពលរបស់ប្រទេសមហាអំណាចទាំងនេះ វាកើតឡើងនៅពេលដែលចលនាមនោគមវិជ្ជាកុម្មុយនីស្តបានជ្រាបចូលមកក្នុងប្រទេសកម្ពុជា។ កម្ពុជាបានក្លាយជាសមរភូមិក្នុងការទប់ស្កាត់ និង

ការបង្ករមនោគមវិជ្ជាទាំងនេះ។ ដើម្បីគាំទ្រដល់មនោគមវិជ្ជានីមួយៗ មានប្រទេសមួយចំនួនបានចូលរួមក្នុងបណ្តាប្រទេសណាដែលខ្លួនគិតថាត្រឹមត្រូវទៅតាមការគិតរបស់គេរៀងៗខ្លួន។

ដោយសារតែគំនិតនេះ ដែលបានធ្វើឱ្យប្រទេសកម្ពុជាពេលខ្លះបានក្លាយទៅជាប្រទេសមានសន្តិភាព ឬ សង្គ្រាមបង្ហូរឈាម គឺដោយសារតែឥទ្ធិពលនិងកម្លាំងនៃមនោគមវិជ្ជារបស់ប្រទេសមហាអំណាចទាំងនោះ។

ការបែកបាក់ក្នុងសង្គមខ្មែរមិនមែនទើបតែកើតមានឡើងក្រោយពីរដ្ឋប្រហារទម្លាក់សម្តេច *នរោត្តម សីហនុ* នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០នោះទេ ការបែកបាក់មានតាំងពីក្នុងសម័យអាណានិគមនិយមបារាំងនិងសង្គមរាស្រ្តនិយមមកម្លេះ។

ដោយសារតែការមិនពេញចិត្តចំពោះរដ្ឋការអាណាព្យាបាលបារាំង ពីសំណាក់ប្រជារាស្រ្តខ្មែរទូទៅ និងជាពិសេសពីសំណាក់ពួកបញ្ញវន្តខ្មែរខ្លះ ទើបបណ្តាលឱ្យមានផ្ទុះឡើងនូវចលនាបះបោរប្រឆាំងបារាំងកើតមានជាបន្តបន្ទាប់ដូចខាងក្រោម៖

**ចលនាបះបោររបស់អាចារ្យស្វា** (១៨៦៤-១៨៦៦)៖ កងទ័ពអាចារ្យស្វាបានធ្វើការវាយលុកចូលកាន់កាប់ខេត្តទ្រាំង (កំពត តាកែវ) រួចបន្តដំណើរមកកាន់ក្រុងភ្នំពេញ។ កងទ័ពព្រះបាទ*នរោត្តម* ដោយមានជំនួយពីកងទ័ពបារាំងបានវាយកម្ទេចចលនារបស់អាចារ្យស្វា ហើយចាប់អាចារ្យបញ្ជូនទៅឃុំនៅលើកោះកណ្តាលមហាសមុទ្រ។

**ចលនាបះបោររបស់ពោធិ៍កំបោរ** (១៨៦៥-១៨៩១)៖ កងកម្លាំងពោធិ៍កំបោរមានអ្នកចូលរួមប្រហែលមួយម៉ឺននាក់។ ចលនានេះធ្វើសកម្មភាពនៅព្រំដែនឡាវតាមតំបន់សងខាងទន្លេមេគង្គ និងនៅតំបន់ចន្លោះទីក្រុងឧដុង្គនិងភ្នំពេញ។ នៅខែមករា ឆ្នាំ១៨៦៧ កងទ័ពពោធិ៍កំបោរបានបរាជ័យនៅជាយក្រុងភ្នំពេញ។ ពោធិ៍កំបោរបានទៅពួននៅកំពង់ស្វាយ រួចត្រូវកងទ័ពបារាំងចាប់ ហើយសម្លាប់កាត់យកក្បាលមកដោតនៅក្រុងឧដុង្គនៅខែធ្នូ ឆ្នាំ១៨៦៧។

**ចលនាបះបោររបស់ស៊ីវត្ថា** (១៨៦១-១៨៩១)៖ *ស៊ីវត្ថា* ជាបុត្រទីបីរបស់ព្រះបាទ*អង្គឌួង*។ ចលនាបះបោររបស់ស្តេចអង្គនេះ បានកើតមានតាំងពីមុនការដាក់អាណាព្យាបាលពីបារាំងមកម្លេះ។ ចលនានេះបានបង្កការលំបាកយ៉ាងច្រើនដល់ព្រះមហាក្សត្រនិងពួកអាណាព្យាបាលបារាំង។ ពីឆ្នាំ១៨៦១ដល់១៨៦២ កងកម្លាំងស៊ីវត្ថាចូលកាន់កាប់រាជធានីឧដុង្គ។ ព្រះបាទ*នរោត្តម* បានភៀសព្រះកាយទៅប្រទេសសៀម ហើយយាងត្រឡប់មកវិញបន្ទាប់ពីចលនាបះបោរត្រូវបានវាយបង្ក្រាបវិញនៅឆ្នាំ១៨៦២។ *ស៊ីវត្ថា* រត់រួចហើយទៅករទ័ពធ្វើការបះបោរបន្តទៀត។ នៅឆ្នាំ១៨៨៥ ព្រះមហាក្សត្រព្រះបាទ*នរោត្តម* និងរាជការអាណានិគមសាកល្បងធ្វើការចរចាជាមួយ*ស៊ីវត្ថា* តែ*ស៊ីវត្ថា*មិនព្រមទទួលលក្ខខណ្ឌ ហើយបន្តធ្វើការបះបោរទៀត។ នៅឆ្នាំ១៨៩១ *ស៊ីវត្ថា* បានទទួលមរណភាពដោយជំងឺ។ ចលនារបស់*ស៊ីវត្ថា*ក៏រលំរលាយត្រឹមនេះ។

**ចលនាតស៊ូរបស់ក្រឡាហោមគង់** (១៨៨៥-១៨៨៦)៖ កងទ័ពរបស់ក្រឡាហោមគង់ប្រយុទ្ធរំដោះខ្លួនពីអំពើជិះជាន់របស់ពួកអាណានិគមន៍។ ចលនានេះមានការគាំទ្រអំពីកសិករជនជាតិចិនមួយចំនួននិងព្រះសង្ឃ។ នៅឆ្នាំ១៨៨៦ បារាំងបានធ្វើល្បិចអញ្ជើញក្រឡាហោមគង់មកធ្វើការចរចារួចចាប់លោកចងផ្តោបបំពង់ផ្សែងកប៉ាល់រហូតទទួលមរណភាព។

**ចលនាតស៊ូរបស់ពិស្ណុលោកឈូក** (១៨៨៥-១៨៨៦)៖ ក្រុមរបស់ពិស្ណុលោកឈូកបានរួបរួមជាមួយក្រុមរបស់ក្រឡាហោមគង់ដើម្បីប្រយុទ្ធប្រឆាំងនឹងអាណានិគមន៍ ធ្វើឱ្យកងទ័ពបារាំងមានការខូចខាតជាដំណំ។ នៅពេលធ្វើដំណើរមកចូលរួមកិច្ចចរចាតាមសំណើពួកបារាំង លោកបានត្រូវគេលួចធ្វើឃាត។

ក្រោយមក នៅពេលដែលជប៉ុនចូលមកគ្រប់គ្រងប្រទេសកម្ពុជា នៅពេលនោះកម្ពុជាបានបែងចែកជាពីរក្រុមទៀតគឺ ៖ ក្រុមដែលលំអៀងទៅខាងជប៉ុន និង ក្រុមដែលមាននិន្នាការខាងកុម្មុយនិស្ត។

ក្រុមដែលលំអៀងទៅខាងជប៉ុន៖ ក្រុមនេះដឹកនាំដោយលោក *សឺង ង៉ុកថាញ់*។ នៅឆ្នាំ១៩៤៥ ជប៉ុនបានបណ្តេញបារាំងចេញពីកម្ពុជា ហើយប្រកាសកម្ពុជាជារដ្ឋឯករាជ្យ ដោយលើក *សឺង ង៉ុកថាញ់* ឱ្យធ្វើជានាយករដ្ឋមន្រ្តី ដែលតាមការពិតរដ្ឋាភិបាលរបស់ *សឺង ង៉ុកថាញ់* គ្រាន់តែជារដ្ឋាភិបាលទីងមោងនៃឯករាជ្យក្លែងក្លាយដែលផ្តល់ដោយពួកយោធានិយមជប៉ុនប៉ុណ្ណោះ។

ក្រោយពេលជប៉ុនចាញ់សង្រ្គាមលោកលើកទី២ បារាំងបានវិលមកកាន់កម្ពុជាជាថ្មី កងទ័ពរបស់ *សឺង ង៉ុកថាញ់* បានប្រឹងទប់ទល់នឹងបារាំងដែរ តែពុំអាចតស៊ូនឹងបារាំងបានឡើយ ហើយ *សឺង ង៉ុកថាញ់* ត្រូវបានចាប់ខ្លួនយកទៅឃុំនៅប្រទេសបារាំង។ នៅឆ្នាំ១៩៥១ បារាំងបានដោះលែង *សឺង ង៉ុកថាញ់* តាមសំណើរបស់ព្រះមហាក្សត្រខ្មែរ។ នៅដើមឆ្នាំ១៩៥២ *សឺង ង៉ុកថាញ់* បានរត់ទៅប្រទេសថៃបង្កើតចលនាខ្មែរសេរី ។

ក្រុមដែលមាននិន្នាការខាងកុម្មុយនិស្ត ៖ នៅឆ្នាំ១៩៣០ ចលនាប្រជារាស្រ្តបានរួបរួមជាមួយក្រុមដែលមាននិន្នាការខាងកុម្មុយនិស្ត។ ចលនាតស៊ូរំដោះជាតិនៅក្នុងប្រទេសកម្ពុជា បានវិវត្តទៅដោយមានទំនាក់ទំនងដោយស្អិតរមួតទៅនឹងចលនារំដោះជាតិវៀតណាមនិងឡាវ។

ដោយយោងទៅតាមសេចក្តីសម្រេចចិត្តនៃការប្រជុំពេញអង្គរបស់គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តឥណ្ឌូចិនលើកទី៦និងលើកទី៧ ពួកកុម្មុយនីស្ត កម្មាភិបាល កងទ័ពប្រជាជនវៀតណាមបានធ្វើសកម្មភាពគាំទ្រដល់កងកម្លាំងអ្នកតស៊ូខ្មែរ (ឆ្វេងនិយម) នៅក្នុងសង្រ្គាមឈ្លបប្រឆាំងនឹងពួកអាណានិគមនិយមបារាំង។ ខ្មែរឥស្សរៈបានដើរមុខគេនៅក្នុងចលនាតស៊ូរំដោះជាតិដោយអាវុធនៅក្នុងប្រទេសកម្ពុជា។ ជ័យជម្នះនៃសកម្មភាពរបស់ខ្មែរឥស្សរៈ និងការរីករាលដាលនៃឥទ្ធិពលរបស់ពួកខ្មែរឥស្សរៈ បានធ្វើឱ្យព្រះមហាក្សត្រព្រះបាទ*នរោត្តម សីហនុ* មិនអាចពន្យាពេលតទៅទៀតបាន ព្រោះព្រះអង្គបានមើលឃើញថា ប្រទេសជាតិអាចធ្លាក់ចូលទៅក្នុងកណ្តាប់ដៃរបស់ពួកកុម្មុយនីស្ត ជាពិសេសគឺពួកវៀតមិញ ដែលមានប្រវត្តិសាស្រ្តដ៏ជូរចត់នៅក្នុងវិបត្តិនៃការបាត់បង់ទឹកដីរបស់កម្ពុជា។

បញ្ហានេះក៏ជាហេតុផលមួយដែរ ដែលបារាំងក្រោមការធ្វើអន្តរាគមន៍ពីប្រទេសលោកខាងលិចផងនោះ បារាំងបានប្រគល់ឯករាជ្យឱ្យកម្ពុជានៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ហើយបារាំងយល់ថា មានតែសម្តេច *នរោត្តម សីហនុ* ទេ ដែលអាចធានាថា ប្រទេសកម្ពុជានឹងមិនក្លាយជាសត្រូវនឹងបារាំងក្រោមឥទ្ធិពលមនោគមវិជ្ជាសង្រ្គាមត្រជាក់។

យើងសូមធ្វើការកត់សម្គាល់ផងដែរថា ក្នុងដំណាក់កាលឆ្នាំ១៩៥០-១៩៥៣ រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកនិងពង្រឹងការគ្រប់គ្រងរដ្ឋបាលយោធានៅលើតំបន់ទាំងឡាយណា ដែលស្ថិតនៅក្រោមការធ្វើសកម្មភាពពីតំណាងខ្មែរឥស្សរៈ។ នៅពេលនោះ អ្នកកាន់អំណាចបានរៀបចំប្រតិបត្តិការ

បង្កើតកម្លាំងប្រជាកសិករ ជាពិសេសនៅតាមខេត្តទាំងឡាយណានៃប្រទេសកម្ពុជាដែលជាមូលដ្ឋានកម្លាំងរបស់ខ្មែរឥស្សរៈ។

ប្រតិបត្តិការមួយមានឈ្មោះថា **ប្រតិបត្តិការសាមគ្គី** ត្រូវបានបង្កើតឡើងដើម្បីបោសសំអាតពួកខ្មែរឥស្សរៈ ដែលបានធ្វើឡើងក្រោមព្រះរាជតម្រិះរបស់ព្រះមហាក្សត្រព្រះបាទ*នរោត្តម សីហនុ* ទៅលើពួកឆ្វេងនិយម។ មុននឹងចាប់ផ្តើមប្រតិបត្តិការនេះ រាជរដ្ឋាភិបាលបានធ្វើការចោទប្រកាន់ទៅលើពួកខ្មែរឥស្សរៈថា ពួកនេះបានធ្វើការសហការជាមួយនឹងពួកវៀតមិញ។ បន្ទាប់ពីខែវិច្ឆិកា ឆ្នាំ១៩៥៣ ពួកខ្មែរឥស្សរៈបានក្លាយជាសត្រូវកាន់តែខ្លាំងនៅក្នុងការតស៊ូដើម្បីឯករាជជាតិ។

ចំពោះសង្គ្រាមដែលពួកវៀតមិញបានធ្វើសកម្មភាពជួយដល់ខ្មែរឥស្សរៈក្នុងការប្រឆាំងនឹងពួកអាណានិគមនិយមបារាំងនៅលើទឹកដីកម្ពុជា ត្រូវបានចាត់ទុកថា ជាសកម្មភាពឈ្លានពានរបស់ពួកវៀតមិញមកលើប្រទេសកម្ពុជា ហើយពួកខ្មែរឥស្សរៈជាក្រុមខ្មែរមួយធ្វើសកម្មភាពតាមបទបញ្ជារបស់ពួកវៀតមិញ ចាប់ពីពេលនោះមក សកម្មភាពប្រឆាំងនឹងពួកខ្មែរឥស្សរៈនិងពួកវៀតមិញកាន់តែមានសកម្មភាពខ្លាំងឡើងៗ។

ប្រតិបត្តិការនេះ បានចាប់ផ្តើមបន្ទាប់ពីបារាំងបានប្រគល់អំណាចយោធាទាំងស្រុងមកឱ្យរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្ហាញពិភពលោកទាំងមូលឱ្យឃើញថា របបរាជានិយមកម្ពុជាមិនត្រឹមតែមានចលនាតស៊ូដើម្បីឯករាជ្យជាតិប៉ុណ្ណោះទេ ប៉ុន្តែយើងបានបំពេញនូលលក្ខន្តិកៈផ្សេងៗទៀតបានថែមទៀងផងដែរ ដែលមានចែងនៅក្នុងការទទួលឯករាជ្យជាតិ។ លក្ខន្តិកៈមួយក្នុងលក្ខន្តិកៈជាច្រើននោះ គឺការប្រឆាំងនឹងពួកឆ្វេងនិយមដែលព្រះបាទសម្តេចព្រះ*នរោត្តម សីហនុ* បានសន្យាថា នឹងដឹកនាំនយោបាយតឹងរ៉ឹងជាទីបំផុតនោះ។

រហូតដល់ការចាប់ផ្តើមសន្និសីទនាទីក្រុងហ្សឺណែវ ការប្រឈមមុខដាក់គ្នារវាងកងទ័ពនៃរាជរដ្ឋាភិបាលនិងកងទ័ពរបស់ខ្មែរឥស្សរៈពុំបានបញ្ឈប់ទេ ពីព្រោះកម្លាំងតស៊ូរបស់ខ្មែរឥស្សរៈយល់ឃើញថា ប្រទេសកម្ពុជាបានស្ថិតនៅក្នុងសមាជិកភាពបារាំងនៅឡើយ។ ម្យ៉ាងទៀត ប្រទេសវៀតណាមនិងឡាវ ដែលជាអ្នករួមអាវុធជាមួយគ្នានោះ ពុំទាន់បានឯករាជ្យនៅឡើយ។

នៅចុងឆ្នាំ១៩៥៣ និងដើមឆ្នាំ១៩៥៤ ជាដំណាក់កាលមួយដែលចលនាកងឈ្លបខ្មែរឥស្សរៈបានធ្វើសកម្មភាពនៅលើពេញផ្ទៃប្រទេស។ ដោយមានការវាយលុកយ៉ាងខ្លាំងក្លាពីសំណាក់កងទ័ពខ្មែរឥស្សរៈនិងពួកវៀតមិញលើទឹកដីកម្ពុជា ដូច្នេះនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៥៤ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ញត្តិថ្កោលទោសដល់សកម្មភាពឈ្លានពានរបស់ពួកវៀតណាមមកលើកម្ពុជាមួយច្បាប់ជូនចំពោះអង្គការសហប្រជាជាតិ។ រាជរដ្ឋាភិបាលកម្ពុជា បានសម្តែងនូវការប្រឆាំងចំពោះការរំលោករបស់កងទ័ពវៀតមិញមកលើដែនអធិបតេយ្យភាពរបស់កម្ពុជា និងបានថ្កោលទោសយ៉ាងខ្លាំងដល់សកម្មភាពឈ្លានពានរបស់ពួកវៀតមិញមកលើទឹកដីកម្ពុជា។

យោងតាមកិច្ចព្រមព្រៀងនៃសន្និសីទក្រុងហ្សឺណែវនាថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៥៤ ស្តីពីការបញ្ឈប់បទឈប់បាញ់គ្នានៅក្នុងប្រទេសកម្ពុជា និងការបញ្ឈប់សកម្មភាពយោធានៅក្នុងប្រទេសកម្ពុជាដែលបានចុះហត្ថលេខាដោយតំណាងភាគីកម្ពុជា វៀតណាម និង កងទ័ពខ្មែរឥស្សរៈ សកម្មភាពប៉ះទង្គិចគ្នាដោយយោធាត្រូវបញ្ឈប់ទាំងស្រុងចាប់ពីថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៥៤។ ចំពោះកម្លាំងទ័ពខ្មែរឥស្សរៈត្រូវរំសាយក្នុងកំឡុង៣០ថ្ងៃក្រោយកិច្ចព្រមព្រៀងនោះ។

ការគ្រប់គ្រងចំពោះការអនុវត្តបំពេញលក្ខន្តិកៈតាមកិច្ចព្រមព្រៀងស្តីអំពីបញ្ហាកម្ពុជា គេបានបង្កើតគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (The International Commission for Control = ICC) ដែលក្នុងនោះ មានការចូលរួមដោយតំណាងពីប្រទេសឥណ្ឌា កាណាដា និងប៉ូឡូញ។

ទន្ទឹមនឹងនេះដែរ គេបានបង្កើតគណៈកម្មការរួមខ្មែរ-វៀតណាម ក្រោមការត្រួតពិនិត្យឃ្លាំមើលពីសំណាក់ ICC គណៈកម្មការមានការងារជាពិសេស គឺការពិនិត្យមើលសកម្មភាពនៃការដកកងទ័ពបរទេសចេញពីទឹកដីកម្ពុជា។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៥៤ កងទ័ពជាតិវៀតណាមបានដកចេញទាំងស្រុងពីទឹកដីនៃប្រទេសកម្ពុជា ហើយក្នុងកំឡុងខែសីហា និងខែកញ្ញា កងទ័ពខ្មែរឥស្សរៈត្រូវបានរំសាយ។

សន្តិភាពក្នុងដំណាក់កាលនោះមានអាយុតែជាងមួយទសវត្សរ៍ប៉ុណ្ណោះ។ ក្នុងខណៈដែលនយោបាយក្នុងការដឹកនាំប្រទេសរបស់សម្តេច*នរោត្តម សីហនុ* មានការប្រែប្រួលដោយមានការបង្កើតទំនាក់ទំនងជាមួយបណ្តាប្រទេសសង្គមនិយម ជាពិសេសប្រទេសចិននិងហសភាពសូវៀតនោះ បានធ្វើប៉ះទង្គិចដល់ឥទ្ធិពលនៃទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក។ ដោយសារតែអាមេរិកមានទំនាក់ទំនងជាមួយប្រទេសថៃនិងវៀតណាមខាងត្បូង ពេលនោះប្រទេសទាំងពីរក្រោមឥទ្ធិពលអាមេរិកបានបង្កើតបញ្ហានៅតាមព្រំដែននៃប្រទេសទាំងពីរ។

ចាប់ខែមករា ដល់ខែកក្កដា ឆ្នាំ១៩៥៨ កងទ័ពវៀតណាមខាងត្បូងបានធ្វើការលុកលុយមកលើទឹកដីកម្ពុជានៅតាមព្រំប្រទល់នៃប្រទាំងពីរជាច្រើនលើក។ រីឯសភាពការណ៍នៅតាមព្រំដែនទល់នឹងប្រទេសថៃឯណោះវិញក៏ដូច្នេះដែរ វិទ្ធង្សនាយោធាពុំបានបញ្ឈប់ទេ គឺកងទ័ពថៃបានធ្វើសកម្មភាពជាច្រើនលើកផងដែរមកលើទឹកដីកម្ពុជា ជាពិសេសថៃបានលើកកម្លាំងមកកាន់កាប់ប្រាសាទព្រះវិហារទាំងខុសច្បាប់ទៀតផង។

ក្រៅពីកម្លាំងប្រឆាំងនឹងនយោបាយរបស់សម្តេចព្រះ*នរោត្តម សីហនុ* ពីប្រទេសជិតខាងដែលស្និទ្ធនឹងអាមេរិកនោះ នៅឯក្នុងប្រទេសវិញ យើងក៏ឃើញមានការបង្កើតក្រុមប្រឆាំងនឹងព្រះអង្គផងដែរ។ នៅឆ្នាំ១៩៦៣ លោក សាឡុតស (ប៉ុលពត) និងលោក ស៊ុន សេន បានបង្កើតក្រុមឧទ្ទាមទ័ពព្រៃ (ខ្មែរក្រហម ត្រូវបានឧបត្ថម្ភនិងគាំទ្រដោយប្រទេសចិនកុម្មុយនីស្ត) ហើយឆ្នាំ១៩៦៦ ការបង្កើតចលនាទ័ពខ្មែរសេរី (Free Khmer) ចលនានេះ ត្រូវបានឧបត្ថម្ភនិងគាំទ្រដោយប្រទេសថៃ និងសហរដ្ឋអាមេរិក ដើម្បីប្រឆាំងនឹងរដ្ឋាភិបាលដែលដឹកនាំដោយសម្តេចព្រះ*នរោត្តម សីហនុ*។ នៅចុងទសវត្សរ៍ឆ្នាំ៦០ស្ថានភាពនយោបាយនៅកម្ពុជាកាន់តែដុនដាបទៅៗ។

នៅក្នុងលក្ខន្តិកៈនៃការលេចឡើងនូវអស្ថិភាពនិងស្ថានភាពកាន់តែលង់ជឿទៅៗ នៃសង្គ្រាមស៊ីវិល នៅក្នុងប្រទេសកម្ពុជាបានធ្វើផ្ទុះឡើងនូវការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងការទម្លាក់សម្តេចព្រះ*នរោត្តម សីហនុ*ចេញពីអំណាច។

នៅថ្ងៃ០៤ ខែឧសភាឆ្នាំ១៩៧០ សម្តេចព្រះ*នរោត្តម សីហនុ* បានបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិមួយ ឬហៅថាសហភាពកម្ពុជា ហើយអំពាវនាវឱ្យប្រជាជនខ្មែរក្រោកឈរឡើង ដើម្បីប្រឆាំងនឹងរដ្ឋាភិបាលរបស់ *លន់ នល់*។ ដោយសារតែការអំពាវនាវរបស់សម្តេចព្រះ*នរោត្តម សីហនុ* នៅពេលនោះយើងឃើញប្រជាកសិករខ្មែរជាច្រើនកន្លែងបានងើបឡើងធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាល *លន់ នល់* និងនាំគ្នារត់ចូលព្រៃក្នុងគោលបំណងគាំទ្រដល់សម្តេចព្រះ*នរោត្តម សីហនុ*។

កម្លាំងដែលស្មោះត្រង់នឹងសម្តេចព្រះ*នរោត្តម សីហនុ* រួមផ្សំនឹងកម្លាំងរបស់ខ្មែរក្រហម បានធ្វើឱ្យសមាសភាពប្រឆាំងនឹងរដ្ឋាភិបាល *លន់ នល់* បានកើនឡើងយ៉ាងឆាប់រហ័ស។ ទីបំផុតនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមដែលដឹកនាំដោយប៉ុលពតបានបញ្ចប់សម័យសាធារណរដ្ឋខ្មែរចេញពីអំណាច និងបានដណ្តើមកាន់កាប់យកទីក្រុងភ្នំពេញ ហើយជំលៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ ដោយបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ។

ការបញ្ចប់ទៅនៃរបបសាធារណរដ្ឋខ្មែរ មិនអាចធ្វើឱ្យសង្គមខ្មែរមានការរីកចម្រើន និង សុខសន្តិភាពបានឡើង ហើយថែមទាំងធ្វើឱ្យសង្គមកម្ពុជាជួបនូវការលំបាកគ្រប់បែបយ៉ាងជាងសម័យណាៗទាំងអស់។ ការធ្វើឱ្យសង្គមកម្ពុជាវិលទៅរករបបកុម្មុយនីស្តបុព្វកាល បង្អត់អាហារ ធ្វើទារុណកម្ម និងកាប់សម្លាប់យ៉ាងរង្គាល ទង្វើនេះ បានធ្វើឱ្យមានការប្រឆាំងនឹងគំនិតដឹកនាំរបស់កម្ពុជប្រជា-ធិបតេយ្យ។

នៅខែមេសា ឆ្នាំ១៩៧៦ លោក *ហ៊ូ នឹម* ដែលជារដ្ឋមន្ត្រីក្រសួងឃោសនាការរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានចេញមុខប្រឆាំងនឹង *ប៉ុល ពត*។ នៅខែមីនា ឆ្នាំ១៩៧៦ ប្រជាជននៅចម្ការហ្លួង និងនៅខេត្តសៀមរាប បានទាមទារឱ្យតម្លើងកម្រិតជីវភាពនិងឱ្យគ្រួសារបានរស់នៅជួបជុំគ្នា ហើយនៅដើមខែមករា ឆ្នាំ១៩៧៧ ប្រជាជនខេត្តសៀមរាបភាគខាងជើង និងនៅខេត្តបាត់ដំបងបានក្រោកឈរឡើងបង្កើតជាចលនាប្រឆាំងនឹងពួក *ប៉ុល ពត* ហើយនៅខែមីនា និងមេសា ឆ្នាំ១៩៧៧ ប្រជាជននៅខេត្តកំពង់ធំ មណ្ឌលគីរី កំពង់ឆ្នាំង ក៏បានបង្កើតចលនាប្រឆាំងនឹងពួក *ប៉ុល ពត* ដែរ។

មហាសន្និបាតតំណាងកម្លាំងរំដោះគ្រប់តំបន់ទូទាំងប្រទេស ក្រោមការដឹកនាំរបស់អ្នកស្នេហាជាតិ បានបើកសម័យប្រជុំនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ក្នុងមូលដ្ឋានរំដោះ។ ពេលនោះមហាសន្និបាតបានសម្រេចជាឯកច្ឆន្ទបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងបានបោះឆ្នោតជ្រើសតាំងគណៈកម្មការមជ្ឈឹមរណសិរ្ស ដែលមានសមាជិក១៤ កាលនោះ សម្តេច *ហេង សំរិន* ជាប្រធាន។

ថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃរំដោះទីក្រុងភ្នំពេញឱ្យរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ដោយមានការសហការរវាងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពស្ម័គ្រចិត្តវៀតណាម ហើយក៏បានបង្កើតធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (គ្រប់គ្រងរដ្ឋាភិបាលដោយសម្តេច *ហេង សំរិន*)។

ក្រោយមកនៅថ្ងៃ១៨ ខែកុម្ភៈ ឆ្នាំដដែល សន្ធិសញ្ញាជាមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម ដែលមានវត្តមានជាផ្លូវការណ៍នៃកងទ័ពវៀតណាមលើទឹកដីកម្ពុជា។ ចាប់ពីថ្ងៃចុះសន្ធិសញ្ញានោះរួចមក ចំនួនប្រជាជនវៀតណាមបានចូលមករស់នៅលើទឹកដីកម្ពុជាមានចំនួនកាន់តែច្រើនឡើងៗ។

ក្រោយពីកម្ពុជាប្រជាធិបតេយ្យត្រូវបានដួលរលំហើយ ពួកគេបានរត់ចូលព្រៃតស៊ូ ហើយបង្កអសន្តិសុខដល់ប្រជាជននិងសង្គមកម្ពុជាជាបន្តទៅទៀត។ ដោយមានការឧបត្ថម្ភគាំទ្រពីសំណាក់រដ្ឋាភិបាលចិនកុម្មុយនីស្ត កងទ័ពកម្ពុជាប្រជាធិតេយ្យអាចទប់ទល់នឹងកម្លាំងរដ្ឋាភិបាលនិងកងទ័ពវៀតណាមបាន។

ដោយសារតែវត្តមានកងទ័ពវៀតណាមនៅលើទឹកដីកម្ពុជា បានធ្វើឱ្យសាធារណជនមួយចំនួនយល់ឃើញថា វាជាការឈ្លានរបស់វៀតណាមមកលើបូរណភាពទឹកដីកម្ពុជានោះ បាននាំគ្នាបង្កើតជា

ចលនាតស៊ូប្រឆាំងនឹងរដ្ឋាភិបាលភ្នំពេញ ដែលដឹកនាំដោយសម្តេច *ហេង សំរិន* សម្តេច *ជា ស៊ីម* និងសម្តេច *ហ៊ុន សែន* និងមានការជួយឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលវៀតណាម។ ក្រុមចលនាតស៊ូក្រៅពីកម្ពុជាប្រជាធិបតេយ្យនៅមានពីរក្រុមទៀតគឺ ក្រុមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរដែលដឹកនាំដោយ *សឺន សាន* និងក្រុមរាជនិយមដែលគាំទ្រសម្តេចព្រះ*នរោត្តម សីហនុ*។

ក្នុងខណៈពេលដែលទំនាក់ទំនងទ្វេភាគីរវាងចិន និង អាមេរិក ឈានចូលដល់ការចរចាជាមួយសហភាពសូវៀត បានធ្វើឱ្យសភាពការនយោបាយនៅកម្ពុជាបានវិវត្តទៅមុខគួរឱ្យកត់សម្គាល់ ហើយនៅខែវិច្ឆិកា ឆ្នាំ១៩៨៤ ប្រទេសអឺរ៉ុបខាងលិច ជាពិសេសប្រទេសបារាំងបានរៀបចំគម្រោងការជួបចរចារវាងសម្តេចព្រះ*នរោត្តម សីហនុ* និងតំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ប៉ុន្តែគម្រោងនេះត្រូវបានអាក់ខានទៅវិញ ដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិននិងក្រុមខ្មែរក្រហមមិនយល់ព្រម។

នៅឆ្នាំ១៩៨៥ សភាពការណ៍នយោបាយនៅអាស៊ីបានបើកទិដ្ឋភាពថ្មី អនុគ្រោះដល់ការចរចាសន្តិភាពនៅកម្ពុជា។ ពេលនោះ មានផែនការកាត់បន្ថយរយៈពេលនៃការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា។ ដូច្នេះ កងទ័ពវៀតណាមត្រូវដកចេញពីទឹកដីកម្ពុជាកាន់តែមានលក្ខណៈប្រសើរឡើង។ ប្រទេសអឺរ៉ុបខាងលិចចង់ឱ្យមានការជួបចរចាផ្ទាល់រវាងភាគីជម្លោះ គឺរដ្ឋាភិបាលត្រីភាគីជាមួយប្រទេសវៀតណាម ដោយដាក់លក្ខខណ្ឌឱ្យដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា ទើបចាប់ផ្តើមចរចានិងដោះស្រាយដោយអង្គការសហប្រជាជាតិ។

ដោយសារតែមានអន្តរាគមន៍ពីសហគមន៍អន្តរជាតិនេះហើយ ដែលបង្កើតឱ្យមានការជួបគ្នារវាងសម្តេចព្រះបាទនរោត្តម *សីហនុ* ឯកឧត្តម *ហ៊ុន សែន* ជាលើកដំបូងនៅហ្វែរ-តារដឺន័រ (Fère-Tardenois) ជិតទីក្រុងប៉ារីស ប្រទេសបារាំង កាលពីថ្ងៃទី២-៤ ខែធ្នូ ឆ្នាំ១៩៨៧។ ជំនួបរបៀបនេះបានបន្តរហូតបង្កើតបានឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលមានសម្តេចព្រះ*នរោត្តម សីហនុ* ជាព្រះប្រធាន។

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មានសន្និសីទអន្តរជាតិមួយនៅក្រុងប៉ារីសបានសម្រេចកិច្ចព្រមព្រៀងជាដំណោះស្រាយទូទៅនៃបញ្ហាខ្មែរមួយ ដោយមានរដ្ឋាភិបាល១៨ប្រទេសដែលទាក់ទិននឹងរឿងខ្មែរ បានចុះហត្ថលេខាទទួលស្គាល់សេចក្តីព្រមព្រៀងទាំងនោះ។ សន្ធិសញ្ញាក្រុងប៉ារីសនៃថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១នេះ ត្រូវបានក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ទទួលគាំទ្រថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩១។

យោងតាមកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារី កម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រនៅថ្ងៃទី២៣-២៤-២៥ ខែឧសភា ឆ្នាំ១៩៩៣ ដោយមានគណបក្សនយោបាយចំនួន២០ចូលរួម។ ជាលទ្ធផលយើងឃើញថា ក្នុងចំណោមសន្លឹកឆ្នោតជាងបួនលានសន្លឹក គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន៥៨កៅអី គណបក្សប្រជាជនកម្ពុជាទទួលបាន៥១កៅអី។ គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ទទួលបាន១០កៅអី ហើយគណបក្សចុងក្រោយ គឺគណបក្សម៉ូលីណាកាទទួលបាន០១កៅអី នៅក្នុងសភាធម្មនុញ្ញ ហើយគណបក្សទាំងបួននេះបានរួមគ្នាបង្កើតជារាជរដ្ឋាភិបាលចម្រុះមួយឡើង។

ទោះបីជាមានការស្រុះស្រួលគ្នាក្នុងការបង្កើតរាជរដ្ឋាភិបាលចម្រុះក្តី និងមានការជួយអន្តរា-គមន៍ពីអង្គការសហប្រជាជាតិក្តី ប៉ុន្តែក្នុងដំណាក់កាលនោះ កម្ពុជាមិនអាចបញ្ចប់សង្គ្រាមបានឡើយ។

*តើកត្តាសំខាន់អ្វីខ្លះដែលជាគន្លឹះក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា?*

យើងអាចធ្វើការវាយតម្លៃជារួមថា កត្តាដែលធ្វើឱ្យកម្ពុជាមានអាចបញ្ចប់សង្គ្រាម ប្រទេសមានសុខសន្តិភាពនេះមានកត្តាបីសំខាន់គឺ កត្តាសកល កត្តាតំបន់ និងកត្តាកម្ពុជាខ្លួនឯង។

**កត្តាសកល** បើពិភពលោកមិនមានការប្រែប្រួលផ្នែកនយោបាយទេ (ការបញ្ចប់សង្គ្រាមត្រជាក់) កម្ពុជាមិនអាចឈានទៅរកការចរចារវាងសម្តេចព្រះ*នរោត្តម សីហនុ* និង សម្តេច *ហ៊ុន សែន* ដែរ ហើយបើគ្មានការចរចានេះទេ ក៏គូភាគី ក្នុងសង្គ្រាមស៊ីវិលខ្មែរ មិនអាចចុះកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ តុលា ១៩៩១ គឺ២ឆ្នាំក្រោយជញ្ជាំងប៊ែរឡាំងដួលរលំបានដែរ ហើយក៏គ្មានការបោះឆ្នោតឆ្នាំ១៩៩៣ដែរ។

ការបញ្ចប់សង្គ្រាមត្រជាក់ បានបើកផ្លូវឱ្យមានដំណោះស្រាយសង្គ្រាមស៊ីវិលរ៉ាំរ៉ៃនៅកម្ពុជា។ នៅក្នុងអំឡុងសង្គ្រាមត្រជាក់ កម្ពុជា ក៏ដូចជាបណ្តាប្រទេសភាគច្រើនផ្សេងទៀតដែរ ត្រូវបានប្រទេសមហាអំណាចយកមកធ្វើជាល្បែងប្រជែងអំណាចគ្នា។

បើទោះបីជាគ្មានជញ្ជាំងដូចនៅប៊ែរឡាំង ក៏ប៉ុន្តែ កម្ពុជានៅពេលនោះ ក៏ត្រូវពុះចែកជាពីរដែរ គឺម្ខាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាគាំទ្រដោយវៀតណាមនិងប្លុកសូវៀត និងម្ខាងទៀតគឺរដ្ឋាភិបាលចម្រុះត្រីភាគី ដែលរួមមានក្រុមខ្មែរក្រហមផងនោះ គាំទ្រដោយប្លុកអាមេរិក និង ចិន ដែលជាសម្ព័ន្ធមិត្តក្នុងដំណាក់កាលនោះ បានធ្វើឱ្យប្រជាជនកម្ពុជារាប់លាននាក់ត្រូវស្លាប់និងរងទុក្ខវេទនាដោយសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃនេះ។

នៅឆ្នាំ១៩៨៩ នៅពេលដែលសង្គ្រាមត្រជាក់បានឈានមកដល់ទីបញ្ចប់ សហភាពសូវៀតត្រូវរង្គោះរង្គើ កងទ័ពវៀតណាមក៏បានដកចេញពីកម្ពុជា។ ការចរចារវាងភាគីជម្លោះកម្ពុជា ដែលបានចាប់ផ្តើមធ្វើខ្លះៗហើយនោះ ក៏ចាប់ផ្តើមជឿនលឿនទៅមុខ ក្រោមការជ្រោមជ្រែងរបស់ប្រទេសមហាអំណាច រហូតបានចុះកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ តុលា ១៩៩១។

ថ្វីដ្បិតតែមានបញ្ហាចម្រូងចម្រាស់ជាមួយក្រុមខ្មែរក្រហម ការបោះឆ្នោតជាតិនៅឆ្នាំ១៩៩៣ ក៏ដោយ ក៏កម្ពុជាបានបង្កើតជារាជរដ្ឋាភិបាលចម្រុះមួយ ដែលសហគមន៍អន្តរជាតិទទួលស្គាល់ទាំងអស់គ្នា លែងមានរដ្ឋាភិបាលក្នុងស្រុក និងរដ្ឋាភិបាលក្រៅស្រុក ដូចពេលមុនទៀតហើយ។

ដូច្នេះ ការដួលរលំនៃជញ្ជាំងក្រុងប៊ែរឡាំង ក៏ជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏សំខាន់មួយដែរ សម្រាប់ប្រជាជនខ្មែរ។ ការដួលរលំនៃជញ្ជាំងនេះហើយ ដែលជាចំណុចចាប់ផ្តើមនៃការដួលរលំជញ្ជាំងពុះចែកគូបដិបក្ខក្នុងសង្គ្រាមស៊ីវិលខ្មែរ។

**កត្តាតំបន់**

បញ្ហាតំបន់ក៏ជាបញ្ហាសំខាន់ណាស់ដែរក្នុងបញ្ហាសង្គ្រាមនៅកម្ពុជា ជាពិសេសមហិច្ឆតារបស់ប្រទេសជិតខាងកម្ពុជាពីរ គឺប្រទេសវៀតណាមនិងប្រទេសថៃ។ ជាច្រើនសតវត្សមកហើយដែលប្រទេសថៃនិងប្រទេសវៀតណាមតែងចាត់ទុកកម្ពុជាជាប្រទេសដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួន។

ការវិវត្តនយោបាយក្នុងតំបន់ វាមានសារៈសំខាន់ណាស់សម្រាប់ការបញ្ចប់សង្គ្រាមនៅកម្ពុជា។ យើងអាចនិយាយបានថា បើគ្មានការវិវត្តនយោបាយពិភពលោក ក៏គ្មានការវិវត្តនយោបាយក្នុងតំបន់

ដែរ។ ដូច្នេះ បើរុស្ស៊ីមិនដូរនយោបាយទេ នោះវៀតណាមក៏មិនដូរនយោបាយដែរ ហើយវៀតណាមក៏មិនព្រមដកកងទ័ពរបស់ខ្លួនចេញពីកម្ពុជាដែរ។

នៅពេលដែលវៀតណាមមិនព្រមដកកងទ័ពរបស់ខ្លួនចេញពីកម្ពុជា ប្រទេសថៃក៏មិនបញ្ឈប់ការជួយឧបត្ថម្ភដល់ចលនាតស៊ូត្រីភាគីដែរ ដែលធ្វើឱ្យពួកនេះមានលទ្ធភាពប្រឆាំងនឹងរដ្ឋាភិបាលភ្នំពេញដដែល។ នៅពេលដែលកម្លាំងទាំងសងខាងមានការជួយឧបត្ថម្ភ ដូច្នេះសង្គ្រាមមិនអាចបញ្ចប់បានទេ ព្រោះកម្លាំងទាំងសងខាងមានភាពរឹងមាំដូចគ្នា ដូច្នេះកម្ពុជានៅតែមានសង្គ្រាម។

ដោយសារតែការដកកងទ័ពវៀតណាមចេញពីកម្ពុជា ទើបថៃលែងមានលេសក្នុងការជួយឧបត្ថម្ភគាំទ្រផ្តល់ជម្រកដល់ពួកខ្មែរក្រហម។ ពេលថៃឈប់ឧបត្ថម្ភដល់លពួកខ្មែរក្រហម ទើបធ្វើឱ្យកម្លាំងរបស់ខ្មែរក្រហមចុះខ្សោយ។ ដោយសារកម្លាំងពួកខ្មែរក្រហមចុះខ្សោយ ទើបរាជរដ្ឋាភិបាលមានលទ្ធភាពអាចកម្ចាត់ពួកខ្មែរក្រហមបាន ពេលកម្ចាត់ពួកខ្មែរក្រហមបាន ទើបកម្ពុជាមានសន្តិភាព។

**កត្តាកម្ពុជាខ្លួនឯង៖** នៅពេលដែលពិភពលោកមានការប្រែប្រួល នាំឱ្យតំបន់មានការប្រែប្រួល ហើយការប្រែប្រួលពិភពលោកនិងតំបន់នេះហើយដែលធ្វើឱ្យកម្ពុជាខ្លួនឯងក៏ប្រែប្រួលដែរ ព្រោះកម្ពុជាមិនអាចរស់នៅឯកោតែម្នាក់ឯងនោះទេ។

ដូច្នេះ នៅពេលនោះហើយដែលកម្ពុជាត្រូវមានដំណោះស្រាយមួយសម្រាប់កម្ពុជាខ្លួនឯង គឺកិច្ចចរចាជាមួយមេដឹកនាំនៃចលនាតស៊ូត្រីភាគី ដែលមានសម្តេចព្រះ*នរោត្តម សីហនុ* ជាអ្នកតំណាង ហើយជំនួបរវាងថ្នាក់ដឹកនាំទាំងពីបានប្រព្រឹត្តទៅតាំងពីដើមឆ្នាំ១៩៨៧។ ក្រោយមកនៅឆ្នាំ១៩៨៩ រដ្ឋាភិបាលភ្នំពេញបានសម្រេចក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក្នុងការកែប្រែប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន គឺប្រែពីប្រព័ន្ធសេដ្ឋកិច្ចបែបកុម្មុយនីស្តនិយម មកជាប្រព័ន្ធសេដ្ឋកិច្ចបែបសេរីនិយមវិញម្តង។

ត្រង់ចំណុចនេះយើងអាចនិយាយបានថា វាជាការទទួលរងនូវឥទ្ធិពលនៃការប្រែប្រួលរបស់ពិភពលោកនិងតំបន់។ ព្រោះមុននេះយើងឃើញថា សហភាពសូវៀត ដែលជាមេកុម្មុយនីស្តក្នុងពិភពលោក និងក្រោយមកវៀតណាមដែលជាមេកុម្មុយនីស្តក្នុងតំបន់ បានផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចរបស់ខ្លួន ហើយប្រទេសទាំងពីរជាអ្នកដែលបានជួយឧបត្ថម្ភដល់កម្ពុជា ក្នុងដំណាក់កាលនៃការស្តារប្រទេសឡើងវិញក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត)។

ដោយខ្វះការទីពឹងក្នុងការទ្រទ្រង់ជីវិតនយោបាយរបស់ខ្លួននៅពេលនោះ កម្ពុជាក៏បានផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចរបស់ខ្លួនដែរ ហើយការផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចសេរីនេះ កម្ពុជាមិនអាចខ្វះដៃគូវិនិយោគបានឡើយ ហើយដើម្បីបានដៃគូក្នុងក្នុងការវិនិយោគ កម្ពុជាត្រូវតែមានស្ថានភាពនយោបាយមួយដែលមានស្ថិរភាព គ្មានសង្គ្រាមដែលធ្វើឱ្យអ្នកវិនិយោគគេមានទំនុកចិត្ត មិនបាត់បង់ដោយសារតែស្ថានភាពនយោបាយរបស់កម្ពុជា។ ការអភិវឌ្ឍប្រទេសមួយបាន ប្រទេសនោះត្រូវតែមានសុខសន្តិភាព មានឯករាជ្យភាព និងអធិបតេយ្យភាព មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេសណាមួយឡើយ។

ដោយមានការជួយខ្នះខ្នែងពីសហគមន៍អន្តរជាតិផង និងដោយយល់ពីស្ថានភាពរបស់ខ្លួនផង ធ្វើឱ្យដំណើរការនៃការចរចារកសន្តិភាពរបស់ប្រទេសកម្ពុជាមានដំណើរការល្អ ដែលបង្កើតឱ្យមានកិច្ចព្រមព្រៀងថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ យោងទៅលើកិច្ចព្រមព្រៀងឆ្នាំ១៩៩១នេះ កម្ពុជាបានឈានទៅដល់ការបោះឆ្នោតឆ្នាំ១៩៩៣ ហើយរបបគ្រប់គ្រងនៅកម្ពុជាបានប្រែក្លាយពីរបបគ្រប់

គ្រងបែបកុម្មុយនីស្តមករបបគ្រប់គ្រងបែបប្រជាធិបតេយ្យសេរីពហុបក្សវិញម្តង ដោយមានការចូលរួមពីគ្រប់ភាគីជម្លោះរបស់ខ្មែរក្នុងអតិតកាល។

តែមុនការបោះឆ្នោតបន្តិចដោយយល់ឃើញថា ខ្លួនមិនអាចមានអំណាចបានតាមរយៈការបោះឆ្នោត ក្រុមខ្មែរក្រហម(ប៉ុលពត) បានគេចចេញពីការបោះឆ្នោត មិនព្រមចូលរួមក្នុងរដ្ឋាភិបាលចម្រុះ ហើយក៏នៅបន្តសកម្មភាពប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាបន្តទៀត។ តែម្តងនេះយើងមើលឃើញថា ខ្មែរក្រហមមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាដូចកាលពីមុនទៀតឡើយ ដោយយោងទៅលើកិច្ចព្រមព្រៀងឆ្នាំ១៩៩១ ខ្មែរក្រហមគ្មានការជួយជ្រមជ្រែងពីសំណាក់បរទេសដូចកាលពីមុនទៀត។

ដូច្នេះខ្មែរក្រហមត្រូវពឹងផ្អែកលើសេដ្ឋកិច្ចផ្ទាល់ខ្លួនខ្លះ ធ្វើយ៉ាងណាដើម្បីបន្តជីវិតនយោបាយរបស់ខ្លួនក្នុងការប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាបន្តទៅទៀត។ នៅក្នុងដំណាក់កាលនោះយើងឃើញថា ខ្មែរក្រហមនៅមានកម្លាំងខ្លាំងក្លានៅឡើយ ព្រោះយើងដឹងហើយថា កម្លាំងតស៊ូដែលមានចំនួនច្រើនជាងគេ គឺក្រុមរបស់ខ្មែរក្រហមនេះឯង ហើយមូលដ្ឋានដ៏រឹងមាំរបស់គេនៅតំបន់អន្លង់វែង និងប៉ៃលិនដែលជាតំបន់មួយសម្បូរទៅដោយធនធានធម្មជាតិរ៉ែនិងព្រៃឈើ។ ធនធានធម្មជាតិបានធ្វើឱ្យជីវិតនយោបាយរបស់ខ្មែរក្រហមអាចបន្តដង្ហើមរបស់ខ្លួនយ៉ាងរឹងមាំបានមួយរយៈ។

ដោយមើលឃើញពីគ្រោះថ្នាក់នេះ រាជរដ្ឋាភិបាលក៏ដាក់ចេញនូវនយោបាយមួយដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជានោះគឺ នយោបាយឈ្នះឈ្នះ ដែលគោលនយោបាយនេះមានធាតុ៥សំខាន់គឺ បំបែក ធ្វើឱ្យឯកា បញ្ចប់ សមាហរណកម្ម និងអភិវឌ្ឍ។

នយោបាយនេះ ជាគន្លឹះមួយយ៉ាងសំខាន់ក្នុងការបញ្ចប់ជីវិតនយោបាយចុងក្រោយរបស់ខ្មែរក្រហម។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានដាក់ក្រុមខ្មែរក្រហមជាក្រុមឧទាមក្រៅច្បាប់ ហើយរាជរដ្ឋាភិបាលបានអនុវត្តនយោបាយឈ្នះឈ្នះដោយផ្តើមចេញពីការបំបែកកម្លាំងរបស់ខ្មែរក្រហម ធ្វើយ៉ាងណាឱ្យពួកខ្មែរក្រហមមិនទុកចិត្តគ្នា ចាប់ផ្តើមសង្ស័យគ្នា ដែលឈានទៅដល់ការបែកបាក់ផ្ទៃក្នុង។ នោះគឺការលើកលែងទោស ការមិនយកទោសរាល់ក្រុមខ្មែរក្រហមទាំងឡាយណា ដែលបានផ្តាច់ខ្លួនពីក្រុមខ្មែរក្រហមក្បាលរឹង ហើយមកចុះចូលជាមួយរាជរដ្ឋាភិបាល ជាមួយនឹងការលើកលែងទោសនេះ រាជរដ្ឋាភិបាលថែមទាំងលើកទឹកចិត្តទៀតផង ដោយរាជរដ្ឋាភិបាលសន្យាផ្តល់ដីធ្លីសម្រាប់ប្រកបរបរក្នុងការរស់នៅទៀតផង។ ជាមួយគ្នានោះដែរ ចំពោះថ្នាក់ដឹកនាំខ្មែរក្រហមវិញ រាជរដ្ឋាភិបាលមិនត្រឹមតែលើកលែងទោសប៉ុណ្ណោះទេ រាជរដ្ឋាភិបាលថែមទាំងផ្តល់តួនាទីតំណែងក្នុងរាជរដ្ឋាភិបាលទៀតផង។

ការមិនទុកចិត្តគ្នារបស់ក្រុមខ្មែរក្រហម ក្រោមនយោបាយបំបែកខ្មែរក្រហមរបស់រាជរដ្ឋាភិបាល និងភាពអស់សង្ឃឹមក្នុងការដណ្តើមជ័យជម្នះរបស់ខ្លួនទៅលើរាជរដ្ឋាភិបាល ហើយដោយមានការបញ្ចុះបញ្ចូលពីថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាលផង បានធ្វើឱ្យក្បាលម៉ាស៊ីនដឹកនាំក្នុងកម្លាំងរបស់ខ្មែរក្រហមចាប់ផ្តើមមានការរង្គោះរង្គើ។

ជាលើកដំបូង ថ្នាក់ដឹកនាំរបស់ខ្មែរក្រហមនៅតំបន់ប៉ៃលិន ដែលជាតំបន់សេដ្ឋកិច្ចដ៏សំខាន់របស់ខ្មែរក្រហម ក្រោមការដឹកនាំរបស់លោក *អៀង សារី* និងលោក *អ៊ី ឈាន* បានផ្តាច់ខ្លួនពីក្រុមខ្មែរ

ក្រហមក្បាលរឹងនៅឆ្នាំ១៩៩៦។ ការផ្តាច់ខ្លួនរបស់លោក *អៀង សារី* ចាត់ទុកថា ជាភាពជោគជ័យមួយដ៏សំខាន់ក្នុងធាតុសំខាន់ទាំង៥នៃនយោបាយឈ្នះឈ្នះ គឺការបំបែក។

ដូច្នេះយើងឃើញថា ការផ្តាច់ខ្លួនរបស់លោក *អៀង សារី* ប្រៀបបានទៅនឹងការបោះដុំថ្មមួយដុំចូលទៅក្នុងផ្ទៃទឹកដែលកំពុងតែស្ងប់ បង្កើតឱ្យមានជារលកដ៏ធំបោកបក់នៅក្នុងក្រុមរបស់ខ្មែរក្រហមបាន។ ចាប់ពីពេលដែលលោក *អៀង សារី* និងលោក *អ៊ី ឈាន* បានផ្តាច់ខ្លួនចូលមករួមរស់ជាមួយរាជរដ្ឋាភិបាលនោះហើយ ដែលធ្វើក្រុមរបស់ខ្មែរក្រហមចាប់ផ្តើមលែងទុកចិត្តគ្នា ហើយមានការសង្ស័យគ្នាទៅវិញទៅមកក្នុងបណ្តាថ្នាក់ដឹកនាំរបស់ខ្មែរក្រហម។ ក្រោយមកយើងឃើញមានការបែកបាក់ដ៏ធ្ងន់ធ្ងររបស់ខ្មែរក្រហមនោះ គឺការសម្លាប់រង្គាលមួយនៅតំបន់អន្លង់វែង ដែលជាតំបន់ដ៏សំខាន់មួយទៀតរបស់ខ្មែរក្រហម គឺការសម្លាប់ក្រុមគ្រួសាររបស់លោក *ស៊ុន សេន* ទាំងពូជន៍ ដោយគេចាត់ទុកថា *ស៊ុន សេន* បានចូលដៃជាមួយពួក*ប៉ុល ពត* យួន ឱ្យការណ៍ទៅយួន។ គ្រួសាររបស់ *ស៊ុន សេន* ត្រូវបានសម្លាប់ដោយ *ប៉ុល ពត*។

ការសម្លាប់របស់គ្រួសារ *ស៊ុន សេន* នេះ ជាលេសមួយដែលនៅពេលនោះ *តាម៉ុក* ដែលជាមេខ្មែរក្រហមក្បាលរឹងបានប្រមូលប្រជាជននៅតំបន់នោះធ្វើការកាត់ទោស ដោយចោទថា ជាមនុស្សឃោរឃៅ ជាឃាតករបានសម្លាប់ផ្តាច់ពូជទៅលើក្រុមគ្រួសាររបស់ *ស៊ុន សេន* គឺ *ប៉ុល ពត* ត្រូវជាប់គុកអស់មួយជីវិត។ ក្រោយមកនៅខែមេសា ឆ្នាំ១៩៩៨ *ប៉ុលពត* ត្រូវបានស្លាប់នៅក្នុងខ្ទម ឃុំឃាំងមួយនៅលើខ្នងភ្នំដងរែកនាព្រំដែនកម្ពុជា-ថៃ។

ការស្លាប់របស់ *ប៉ុល ពត* បានបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀតអំពីការឈានទៅរកភាពរលំរលាយនៃអង្គការចាត់តាំងនិងនយោបាយរបស់ខ្មែរក្រហម។ ដោយអស់ការជឿទុកចិត្តទៅលើតាម៉ុក មេដឹកនាំខ្មែរក្រហមសំខាន់ៗមួយចំនួនដូចជាលោក *ខៀវ សំផន នួន ជា កោ ប៊ុនហេង* ជាដើមបានចូលសារភាពមករួមរស់ជាមួយរាជរដ្ឋាភិបាលផងដែរ។

ក្នុងដំណាក់កាលនោះ ថ្នាក់ដឹកនាំរបស់ខ្មែរក្រហមនៅសល់តែ *តាម៉ុក* ម្នាក់ប៉ុណ្ណោះ ដែលក្បាលរឹង មិនព្រមចូលសារភាពមករួមរស់ជាមួយរាជរដ្ឋាភិបាល។ ក្រៅពីថ្នាក់ដឹកនាំដែលបានផ្តាច់ខ្លួនចូលមករួមរស់ជាមួយរាជរដ្ឋាភិបាល យើងតែងឃើញកងកម្លាំងដែលជាពលទាហានរបស់ខ្មែរក្រហមបាននាំគ្នាផ្តាច់ខ្លួនចូលមករួមរស់ជាមួយរាជរដ្ឋាភិបាលជាបន្តបន្ទាប់។ នេះហើយជាដំណាក់កាលនៃយុទ្ធសាស្ត្រក្នុងការបំបែក ហើយក្រោយមក *តាម៉ុក* ត្រូវនៅឯកោ គ្មានអ្នកគាំទ្រ ដោយត្រូវរត់គៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយ។

ដោយមានការតាមចាប់ពីរាជរដ្ឋាភិបាល *តាម៉ុក* ត្រូវរស់នៅប្រទេសថៃ តែដោយសារមានកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលភ្នំពេញ និងយោងតាមកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩១ ដូច្នេះ *តាម៉ុក* មិនអាចស្នាក់នៅក្នុងប្រទេសថៃដូចកាលពីមុនទៀតទេ ដែលធ្វើឱ្យតាម៉ុកត្រូវសម្រេចចិត្តត្រឡប់ ចូលមកលាក់ខ្លួនក្នុងព្រៃនៃតំបន់ព្រំដែនកម្ពុជា-ថៃវិញ។

ពេលនោះហើយដែល *តាម៉ុក* ត្រូវកម្លាំងរាជរដ្ឋាភិបាលចាប់ខ្លួនបាននៅចុងឆ្នាំ១៩៩៨។ ការចាប់បាន *តាម៉ុក* នេះ ចាត់ទុកថា ជាការបញ្ចប់នយោបាយនិងអង្គការចាត់តាំងរបស់ខ្មែរក្រហមពេលនោះហើយ ដែលរាជរដ្ឋាភិបាលកម្ពុជាប្រកាសថា កម្ពុជាមានសន្តិភាពពេញលេញ លែងមានក្រុម

ឧទ្ទាម ឬតំបន់អបគមន៍បែងចែកទឹកដីទៀតហើយ គឺកម្ពុជាទាំងមូលស្ថិតនៅក្រោមដំបូលនៃព្រះមហាក្សត្រតែមួយព្រះអង្គ រាជរដ្ឋាភិបាលតែមួយ។

ក្រោយពីបញ្ចប់ដំណាក់កាលយុទ្ធសាស្ត្រទី៣នៃការបញ្ចប់អង្គការចាត់តាំង និងនយោបាយរបស់ខ្មែរក្រហម រាជរដ្ឋាភិបាលបានអនុវត្តនូវយុទ្ធសាស្ត្រទី៤ គឺការធ្វើសមាហរណកម្ម។ ការធ្វើដូច្នេះគឺដើម្បីលើកទឹកចិត្តដល់កម្លាំងនៃចលនាតស៊ូទាំងបីភាគី ដោយរាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យកងកម្លាំងទាំងនោះមានលទ្ធភាពក្នុងការរស់នៅក្នុងសង្គម ដោយមានមុខងារនិងតួនាទីក្នុងកងខេមរភូមិន្ទទាំងអស់គ្នា។

ការដែលរាជរដ្ឋាភិបាលធ្វើយ៉ាងនេះ ក្នុងគោលបំណងដើម្បីកុំឱ្យក្រុមនេះមានការអាក់អន់ចិត្តនឹងរាជរដ្ឋាភិបាល ហើយគោរពស្រឡាញ់រដ្ឋាភិបាល ចាត់ទុករាជរដ្ឋាភិបាលជាអាណាព្យាបាលរបស់ខ្លួន មិនទៅបង្កសង្គ្រាមជាមួយរាជរដ្ឋាភិបាលបន្តទៀត។ ដោយសារតែការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលធ្វើឱ្យគេមានជីវភាពដូចប្រជាជនខ្មែរដទៃទៀតដែរ គេរស់នៅដោយស្ងប់ មិនខ្វល់ពីការធ្វើសង្គ្រាមបង្ហូរឈាមដូចកាលពីមុនទៀត។

ដំណាក់កាលចុងក្រោយនៃយុទ្ធសាស្ត្រក្នុងនយោបាយឈ្នះឈ្នះ គឺការអភិវឌ្ឍ។ តំបន់ទាំងឡាយជាអតីតតំបន់ដែលគ្រប់គ្រងដោយចលនាត្រីភាគី ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការប្រែក្លាយតំបន់ទាំងនោះឱ្យទៅជាតំបន់សេដ្ឋកិច្ច តំបន់ទេសចរណ៍ដ៏សំខាន់ តួយ៉ាងដូចជាតំបន់ប៉ៃលិន ត្រូវបានប្រែក្លាយឱ្យទៅជាក្រុងប៉ៃលិន ដោយមានការអភិវឌ្ឍលើគ្រប់វិស័យ។ កាលដើមឡើយតំបន់នេះ ហាក់ ដូចជានៅឆ្ងាយពីសន្តានចិត្តប្រជាជនកម្ពុជា តែក្រោយពីការអភិវឌ្ឍទៅជាក្រុងមកតំបន់នេះហាក់នៅ ជិត ដែលប្រជាជនកម្ពុជាអាចទៅមកបានដោយងាយមិនភ័យព្រួយដូចកាលពីមុនឡើយ។

ក្រៅពីតំបន់ប៉ៃលិន នៅមានតំបន់មួយចំនួនទៀតដូចជា អន្លង់វែង សំឡូត ម៉ាឡៃ ព្រះវិហារជាដើម វាបានក្លាយទៅជាច្រកសេដ្ឋកិច្ចនិងជាតំបន់ទេសចរណ៍ដ៏មានសក្តានុពលសម្រាប់អភិវឌ្ឍជាតិ ហើយបានធ្វើឱ្យតំបន់ទាំងនោះប្រែមុខមាត់ថ្មីពីតំបន់ដាច់ស្រយាល ទៅជាតំបន់ទីប្រជុំជនដែលមានមនុស្សរស់នៅកុះករ មានទេសចរណ៍មិនដាច់។ នេះហើយជាគោលនយោបាយឈ្នះឈ្នះដែលមានន័យមួយទៀតថា ឈ្នះទាំងអស់គ្នា គឺគ្មានអ្នកឈ្នះគ្មានអ្នកចាញ់។ មានសេចក្តីថា ទាំងរាជរដ្ឋាភិបាលទាំងក្រុមចលនាតស៊ូគឺសុទ្ធតែឈ្នះទាំងអស់គ្នា ជារួមគឺកម្ពុជាមានសុខសន្តិភាព លែងមានសង្គ្រាមបង្ហូរឈាមដូចកាលពីមុនទៀត។

នយោបាយឈ្នះឈ្នះ គឺជាស្នូល និងជាឧបករណ៍ដ៏សំខាន់បំផុតនៃទស្សនវិជ្ជាសន្តិភាព។ នយោបាយដែលលើកឡើងនេះ គឺមានន័យថា គ្មានអ្នកចាញ់ គ្មានអ្នកឈ្នះ។ នយោបាយឈ្នះឈ្នះគឺដើម្បីធានាចំពោះសន្តិសុខទាំងអាយុជីវិត ទាំងរូបរាងកាយសម្រាប់មនុស្សទាំងអស់ ដែលបានស្ម័គ្រចិត្តផ្តាច់ខ្លួនពីអង្គការចាត់តាំងខាងនយោបាយនិងយោធារបស់ខ្មែរក្រហម ហើយវិលមករួមរស់ជាមួយរាជរដ្ឋាភិបាលនិងសង្គមជាតិវិញ។

ជាមួយនឹងការធានាខាងលើ ក៏មានការការពារអាជីព និងមុខរបរជូនអ្នកទាំងនោះ តាមរយៈការធ្វើសមាហរណកម្ម និងការរក្សាកម្មសិទ្ធិលើទ្រព្យសម្បត្តិជាអចលនទ្រព្យ និងចលនទ្រព្យរបស់មនុស្សគ្រប់រូបទាំងអស់។ ការធានាទាំងបីយ៉ាងខាងលើ បានឆ្លើយតបយ៉ាងសមស្របចំពោះផល

ប្រយោជន៍របស់បងប្អូនដែលស្ថិតនៅក្នុងជួរខ្មែរក្រហម និងប្រជាជនដែលស្ថិតក្នុងតំបន់ខ្មែរក្រហមកាន់កាប់ ហើយវាបានក្លាយទៅជាអាវុធដ៏ស័ក្តិសិទ្ធ ដែលវាយសំពងទៅលើនយោបាយសង្គ្រាមយោធា និងយុទ្ធសាស្ត្រច្រែះស៊ីដែក របស់ខ្មែរក្រហមដោយត្រូវដួលរលំរលាយទាំងស្រុង។

សន្តិភាព និងការបង្រួបបង្រួមជាតិបានកើតមានឡើងទូទាំងប្រទេស។ ប្រទេសទាំងមូលមានឯកភាពជាតិ ឯកភាពទឹកដី គ្មានតំបន់អបគមន៍ ប្រទេសទាំងមូលស្ថិតនៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយព្រះអង្គ និងរាជរដ្ឋាភិបាលតែមួយ ត្រូវបានកើតឡើងលើទឹកដីដ៏កំសត់នេះដែលជា ឱកាសមាស ពេជ្រ សម្រាប់ការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

ទាំងអស់នេះជាមហាជោគជ័យ ជាកិត្យានុភាព ជាមហាប្រវត្តិសាស្ត្រថ្មីមួយនៅលើទឹកដីកម្ពុជា គឺ ជាការឆ្លុះបញ្ចាំងឱ្យឃើញ នូវការរីកធំធាត់ នៃជំនឿទុកចិត្តលើខ្លួនឯងរបស់ប្រជាជនយើងទាំងអស់គ្នា ហើយក៏ជាការបង្ហាញឱ្យឃើញផងដែរ នូវការកើនឡើងគួរជាទីមោទនៈ នូវតួនាទីរបស់កម្ពុជានៅលើវេទិកាតំបន់ និងក្នុងឆាកអន្តរជាតិនៃពិភពលោកទាំងមូល។

មកដល់ចំណុចនេះយើងអាចនិយាយបានថា ការដែលកម្ពុជាមានសន្តិភាពយ៉ាងនេះ គឺអាស្រ័យដោយកត្តាបីគឺ កត្តាពិភពលោក កត្តាតំបន់ និងកត្តាកម្ពុជាខ្លួនឯង។ បើគ្មានការជួយជ្រោមជ្រែងពីបណ្តាប្រទេសមហាអំណាចក្នុងពិភពលោកទេ នោះវាមិនអាចធ្វើឱ្យប្រទេសក្នុងតំបន់ ជាពិសេសប្រទេសថៃនិងប្រទេសវៀតណាមលែងដៃពីខ្មែរក្រហមនិងរដ្ឋាភិបាលភ្នំពេញឡើយ ហើយកត្តាទាំងពីរខាងលើនេះក៏វាអាស្រ័យដោយលក្ខខណ្ឌប្រជាជាតិកម្ពុជាខ្លួនឯងផងដែរ។ បើគ្មានការយោគយល់ ការអត់ឱន ការអធ្យាស្រ័យគ្នាដោយគិតពីបញ្ហាជាតិជាធំទេ នោះក៏មិនអាចរកសុខសន្តិភាពជូនជាតិមាតុភូមិបានដែរ។

ជារួម យើងអាចទាញបាននូវទិសដៅមួយក្នុងគន្លឹះនៃដំណើរការសន្តិការូបណីយកម្មនៅកម្ពុជាថា៖ ដោយការប្រែប្រួលនៃពិភពលោកនាំឱ្យមានការប្រែប្រួលក្នុងតំបន់ ហើយការប្រែប្រួលក្នុងតំបន់នាំឱ្យមានការប្រែប្រួលក្នុងប្រទេស ហើយការប្រែប្រួលទាំងអស់នោះហើយ ដែលនាំឱ្យមានសន្តិភាពពេញលេញនៅកម្ពុជា។

## ឯកសារយោង


១- កែវ នរិទ្ធ *ការវិភាគលើបញ្ហាត្រូវដោះស្រាយនៅកម្ពុជា* ភ្នំពេញ ខែ មករា ឆ្នាំ ១៩៩៩។

២- កៅ គឹមហួន និង សំរាំង កំសាន្ត *វិធីសាស្ត្រខ្មែរក្នុងការដោះស្រាយទំនាស់* ភ្នំពេញ ឆ្នាំ១៩៩៨។

៣- ខ្លូត ធីតា *ទស្សនវិជ្ជាខ្មែរសម័យ ចតុមុខ លង្វែក ឧដុង្គ និង បារាំង* រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១។

៤- ងែត ហៀន *កិច្ចព្រមព្រៀងហ្សឺណែវ* (ដើម្បីលត់ភ្លើងសង្គ្រាមឥណ្ឌូចិន ប្រែទៅជាដុតភ្លើងសង្គ្រាម ឥណ្ឌូចិនទៅវិញ) ឆ្នាំ ១៩៧១។

៦- ឆាយ សុផល *ហ៊ុន សែន៖ នយោបាយ និង អំណាចក្នុងប្រវត្តិសាស្ត្រខ្មែរជាង៤០ឆ្នាំ* ភ្នំពេញ ឆ្នាំ២០១២។

៧- *ព្រឹត្តិការណ៍ថ្ងៃទី ៥-៦ ខែ កក្កដា ឆ្នាំ ១៩៩៧* ក្រុមការងារពិសេសរបស់រដ្ឋាភិបាល។

៨- ដៀប សុផល *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា* រោងពុម្ពសុខលាភ ឆ្នាំ ២០០៨។

៩- ដៀប សុផល *សង្គ្រាម និង សន្តិភាព កត្តាតំបន់ និង កត្តាសកល ១៩៤៥-១៩៩១* ភ្នំពេញ ឆ្នាំ២០០៥។

១០- ដេវិឌ ឆាណ្ឌល័រ *ប្រវត្តិសាស្ត្រខ្មែរ* បកប្រែពីភាសាអង់គ្លេសដោយមជ្ឈមណ្ឌលខេមរសិក្សា

១១- ត្រឹង ងា *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា* ភាគ ១ + ២ ឆ្នាំ១៩៧១។

១២- ទីឃាយុ *កម្ពុជារបស់សម្ដេច សីហនុ សេចក្ដីសង្ឃឹម ការភ្ញាក់ខ្លួន និង ការតូចចិត្ត* បកប្រែពី Richard Sola, Le Cambodge, Espoir, Désillusions et Amertume។

១៣- ទីឃាយុ *កម្ពុជា ៖ សោកនាដកម្មមួយនៃសម័យយើង* បកប្រែពី Philippe Richer, Le Cambodge Une tragédie de notre temps។

១៤- នួន សុធិមន្ត *សង្គ្រាមអាមេរិកនៅកម្ពុជា លន់ នល់ និង ខ្មែរក្រហម ១៩៧០-១៩៧៥* ភ្នំពេញ ឆ្នាំ២០០៥។

១៥- មជ្ឈមណ្ឌលខេមរសិក្សា ៖ *សិក្សាតំបន់អាស៊ីអាគ្នេយ៍* ភ្នំពេញ ឆ្នាំ២០០៧។

១៦- រស់ ចន្ត្រាបុត្រ *សាធារណរដ្ឋខ្មែរ* ប្រែសម្រួលដោយ ទីឃាយុ។

១៧- រស់ ចន្ត្រាបុត្រ *ប្រវត្តិសាស្ត្រខ្មែរតាមរយៈរឿងព្រេង* ភាគទី១ ។

១៨- វ៉ាន់ឌី កាអុន *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ៖ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល ភាគ១ ២ ៣* ភ្នំពេញ ឆ្នាំ២០១០។

១៩- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា *« ទំនាក់ទំនងអន្តរជាតិ ៖ កម្ពុជាក្រោមក្រសែភ្នែកមហាអំណាច»* ភ្នំពេញ ឆ្នាំ២០០៩។

២០- សាគួ សាមុត *ស្រុកខ្មែរ ការវិវត្តចលនានយោបាយ* ប៉ារីស ថ្ងៃទី២ ខែមីនា ឆ្នាំ២០០០។

២១- សោម សំអ៊ុន *ប្រវត្តិសង្គ្រាមនៅអាស៊ីអាគ្នេយ៍* បោះពុម្ពលើកទី១ដោយបណ្ណាគារពន្លឺវិជ្ជា ឆ្នាំ១៩៧២។

២២- សោម សេកកុមារ *វិបត្តកម្ពុជា និងទំនាក់ទំនងជាមួយបរទេស* ប៉ារីស ខែមករា ឆ្នាំ២០០០។

២៣- សៅ លាង *វាសនា ឬកង្វះទស្សនៈនយោបាយប្រាកដនិយម* ក្រុងប៉ារីស ឆ្នាំ២០០០។

២៤- *ហ៊ុន សែន សុន្ទរកថា ថ្លែងចំពោះមុខរដ្ឋសភាអាណត្តិទីពីរបង្ហាញអំពីកម្មវិធីនយោបាយ និងសកម្មភាពនៃរាជរដ្ឋាភិបាល* ភ្នំពេញទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨។

២៥- ហ៊ុន សែន *ឆ្ពោះទៅឆ្នាំ ២០០០* ខុទ្ទកាល័យ ខែ សីហា ឆ្នាំ១៩៩៩ (ភាគទី២)

២៦- ហ៊ុន សែន *១០ឆ្នាំ នៃដំណើរកម្ពុជា ១៩៧៩-១៩៨៩* ភ្នំពេញ រោងពុម្ព ណុប បូផាន់

២៧- ហ៊ុន សែន *យុទ្ធសាស្រ្តចតុកោណ* ភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤។

២៨- ហេង ហុង *ឱ! លោកជំខ្មែរ "សោកនាដ្យកម្មនៃកម្ពុជា"* ភ្នំពេញ ឆ្នាំ១៩៩៧។

២៩- អ៊ុនតាក់ *កិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជំលោះកម្ពុជា ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១*។

៣០- អេលីហ្សាបែត បេកខ័រ (Elizabeth Becker) *នៅពេលដែលសង្រ្គាមរលត់ទៅ* ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៥។